# អតីតអ្នកសួរចម្លើយរបស់មន្ទីរស-២១បានចំណាយពេលជាច្រើន ឆ្នាំដើម្បីទាញយកចម្លើយសារភាព ប៉ុន្តែនៅពេលនេះមិនហ៊ានសារភាពអ្វីទាំងអស់

*ដោយ ឡូរ៉ា ម៉ាកដូណល់*

*ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

## បញ្ហាដំបូង ៖ ទ្រឹស្តីនៃការប្រព្រឹត្តឧក្រិដ្ឋកម្មរួម ការដាក់ពិរុទ្ធភាពលើខ្លួនឯង និងការចាត់ចែងកន្លែងអង្គុយ

កាលពីម្សិលមិញ អង្គជំនុំជម្រះសាលាដំបូងបានផ្អាកដំណើរការនីតិវិធីមុនពេលកំណត់បន្ទាប់ពីបានជ្រាបថា សាក្សី ម៉ម ណៃ អតីតអ្នកសួរចម្លើយនៅគុកទួលស្លែង (មន្ទីរស-២១) មិនមានមេធាវីធ្វើជាតំណាង ប៉ុន្តែមានបំណងចង់បានមេធាវីដែរតែគ្មានលទ្ធភាព ។ បញ្ហានេះបានកើតឡើងខណៈពេលដែលមេធាវីការពារក្តី ហ្វ្រង់ស្វ័រ រូ បានលើកឡើងពីការព្រួយបារម្ភរបស់លោកដែលថា សាក្សី ម៉ម ណៃ អាចប្រឈមមុខនឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ដោយមូលហេតុថា សេចក្តីសន្និដ្ឋានថ្មីៗរបស់ព្រះរាជអាជ្ញាដែលប្រគល់ជូនចៅក្រម បានស្នើឲ្យចាត់ទុកទ្រឹស្តីនៃការប្រព្រឹត្តឧក្រិដ្ឋកម្មរួមជាវិធីសាស្ត្រកំណត់ការទទួលខុសត្រូវរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចំពោះអង្គជំនុំជម្រះ ។

ទ្រឹស្តីនៃការប្រព្រឹត្តឧក្រិដ្ឋកម្មរួម គឺជាបែបបទដ៏សាំញ៉ាំមួយដែលស្តីពីការទទួលខុសត្រូវរបស់ឧក្រិដ្ឋជនដោយពង្រីកការទទួលខុសត្រូវតាមផ្លូវច្បាប់របស់អ្នកចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្ម តាមគម្រោងផែនការរួមមួយដោយស្មើភាពគ្នា ។ ព្រះរាជអាជ្ញាបានអះអាងថា នឹងមិនធ្វើការកាត់ទោស ម៉ម ណៃ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឡើយ ។ ប៉ុន្តែការអះអាងបែបនេះមិនបានធានាថា ម៉ម ណៃ នឹងរួចផុតពីការកាត់ទោសរបស់តុលាការជាតិនោះទេ ។ ព្រះរាជអាជ្ញាបានចាត់ទុកលទ្ធភាពកាត់ទោសដោយតុលាការជាតិថា ជា«លទ្ធភាពដែលនៅឆ្ងាយ» ។ លោកប្រធានចៅក្រមបានប្រកាសកាលពីពេលថ្មីៗនេះថា ចៅក្រមនឹងចេញសេចក្តីសម្រេចលើសំណុំឯកសារស្តីពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួមស្របពេលជាមួយនឹងការចេញសេចក្តីសម្រេចលើសំណុំរឿងរបស់ ឌុច ។ ដូច្នេះបញ្ហាប្រព្រឹត្តឧក្រិដ្ឋកម្មរួមនៅតែជាបញ្ហាដែលបើកចំហរនៅឡើយទេ ។

ដោយសារតែការប្រព្រឹត្តខុសក្រិដ្ឋកម្មរួមគឺជាលទ្ធភាពដែលអាចកើតឡើងបាន ហើយ ម៉ម ណៃ ក៏ជាអ្នកនៅក្រោមបង្គាប់របស់ ឌុច នោះ ហ្វ្រង់ស៊័រ រូ បានអះអាងថាចៅក្រមគួរតែធានាថាសាក្សី ម៉ម ណៃ បានយល់ដឹងគ្រប់គ្រាន់ពីសិទ្ធិរបស់ខ្លួនក្នុងការមិនឆ្លើយតប សិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯង ។ នៅពេលដែលដឹងថា ម៉ម ណៃ មិនមានមេធាវីជាតំណាង លោកប្រធានចៅក្រមបានទាក់ទងទៅកាន់អង្គភាពរបស់ អ.វ.ត.ក ដើម្បីរកមេធាវីឲ្យ ម៉ម ណៃ ។ លោកប្រធានក៏បានស្នើសុំឲ្យ ម៉ម ណៃ វិលត្រឡប់មកបង្ហាញខ្លួននៅក្នុងអង្គសវនាការវិញនៅថ្ងៃនេះ ។

កាលពីម្សិលមិញ មេធាវីការពារក្ដីហាក់បីដូចជាយល់ពីអារម្មណ៍របស់ ម៉ម ណៃ ។ ប៉ុន្តែនៅពេលបញ្ចេញមតិយោបល់នាព្រឹកនេះ វាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ភាពស្មោះស្ម័គ្ររបស់មេធាវីការពារក្ដីតាមពិតគឺមានតែចំពោះកូនក្ដីរបស់ខ្លួនតែប៉ុណ្ណោះទេ ហើយលោកគ្រាន់តែប្រើប្រាស់ ម៉ម ណៃ ដើម្បីបញ្ជាក់ជូនចៅក្រមថា ទ្រឹស្ដីនៃការប្រព្រឹត្តខុសក្រិដ្ឋកម្មរួមមិនគួរយកមកអនុវត្តនៅក្នុងអង្គជំនុំជម្រះរបស់ ឌុច តែប៉ុណ្ណោះ ។ វីលៀម ស្មីត បានជំទាស់ថា ទ្រឹស្ដីនៃការប្រព្រឹត្តខុសក្រិដ្ឋកម្មរួម មិនបានធ្វើឲ្យមានការផ្លាស់ប្ដូរមកលើករណីឡើងមកឆ្លើយបំភ្លឺរបស់ ម៉ម ណៃ នោះទេ ជាពិសេស គឺទាក់ទិននឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង បើទោះបីជាព្រះរាជអាជ្ញាអាចនឹងប្រើប្រាស់ការទទួលខុសត្រូវដើម្បីចោទប្រកាន់លើ ម៉ម ណៃ ក៏ដោយ ។ ហ្វ្រង់ស៊័រ រូ បានជំទាស់នឹងអ្វីដែល វីលៀម ស្មីត បាននិយាយដោយអះអាងថា ទ្រឹស្ដីនៃការប្រព្រឹត្តខុសក្រិដ្ឋកម្មរួម"មិនមានសារសំខាន់"អ្វីទេ ហើយស្នើសុំឲ្យ វីលៀម ស្មីត ដកសំណុំឯកសារស្ដីពីទ្រឹស្ដីនៃការប្រព្រឹត្តខុសក្រិដ្ឋកម្មរួមនេះចេញ ។

វីលៀម ស្មីត បានចោទប្រកាន់ ហ្វ្រង់ស៊័រ រូ ពីបទរំលោភបំពានវិធានផ្ទៃក្នុង និងពីការគ្រើនរំពុកសាធារណជន និងសាក្សីកាលពីម្សិលមិញ ដោយលើកឡើងពីបញ្ហាការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯងជាសាធារណៈ ។ យោងតាមវិធាន២៨.៨ ប្រសិនបើភាគីណាមួយដឹងថាសក្ខីកម្មរបស់សាក្សីអាចនឹងបង្កឲ្យមានការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង នោះភាគីនោះតម្រូវឲ្យស្នើសុំឲ្យមានអង្គសវនាការសម្ងាត់ និងជម្រាបចៅក្រមជាមុនសិន មុននឹងឡើងមកធ្វើសក្ខីកម្ម ។

ចៅក្រមមិនបានដោះស្រាយបញ្ហាជម្លោះពាក្យសម្ដីលើបញ្ហាទ្រឹស្ដីនៃការប្រព្រឹត្តខុសក្រិដ្ឋកម្មរួមទេ ។ ប៉ុន្តែពេលដែលការធ្វើសក្ខីកម្មរបស់ ម៉ម ណៃ ចាប់ផ្ដើមជាលើកដំបូង លោកប្រធានចៅក្រមបានសួរសំណួរមួយចំនួនដើម្បីបញ្ជាក់ថា សាក្សីពិតជាមានមេធាវីធ្វើជាតំណាង និងបានដឹងពីសិទ្ធិរបស់ខ្លួន ។

លោកប្រធានចៅក្រមកបានបញ្ជាក់ជាមួយនឹង ម៉ម ណៃ ថា ម៉ម ណៃ ពិតជាមានមេធាវីធ្វើជាតំណាងមែន ហើយ ម៉ម ណៃ បានពិភាក្សាជាមួយនឹងមេធាវីរួចហើយ ហើយឥឡូវនេះ ម៉ម ណៃ អាចឆ្លើយនឹងសំណួររបស់ចៅក្រមបាន ។ ជាមួយគ្នានេះលោកប្រធានចៅក្រមក៏បានប្រកាសពីសមាសធាតុរបស់មេធាវីថ្មីដោយធ្វើការពន្យល់ពីមូលហេតុនៃសេចក្តីសម្រេចរបស់អង្គភាពគាំទ្រអ្នកជំនាញ និងសាក្សីដែលសម្រេចជ្រើសរើសមេធាវីរូបនេះ ។ ដូចដែលបានរៀបរាប់កាលពីម្សិលមិញ ជនរងគ្រោះ អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទទំនងជាទទួលបានការខបត្ថម្ភពីអង្គភាពរបស់តុលា-ការ ប៉ុន្តែសម្រាប់ ម៉ម ណៃ ដែលជាសាក្សីដែលមានជាប់ពាក់ព័ន្ធនឹងរឿងក្តីនេះហាក់បីដូចជាមិនទទួលបានការខបត្ថម្ភអ្វីឡើយ ។

បញ្ហាមួយផ្សេងទៀតបានកើតឡើងដោយកាលពីព្រឹកមិញ ហ្វ្រង់ស្វ័រ រ៉ូ បានលើកឡើងពីការព្រួយបារម្ភរបស់លោកដែលថា មេធាវីថ្មីរបស់ ម៉ម ណៃ រូបនេះគួរតែមកអង្គុយនៅកន្លែងមេធាវីការពារក្តី ។ ហ្វ្រង់ស្វ័រ រ៉ូ បាននិយាយថា ការតែងតាំងមេធាវីឲ្យ ម៉ម ណៃ គឺដូចជាការប្រកាសថា ម៉ម ណៃ គឺជាជនជាប់ចោទម្នាក់ដែរ ។ ដូច្នេះ ហ្វ្រង់ស្វ័រ រ៉ូ សូមស្នើសុំឲ្យមេធាវីរូបនេះអង្គុយនៅក្បែរ ម៉ម ណៃ វិញ ។ គួរឲ្យចម្លែក មានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានក្រោកឈរបញ្ចេញយោបល់យល់ស្របជាមួយនឹងការស្នើសុំរបស់មេធាវីការពារក្តី ។ សម្រាប់ព្រះរាជអាជ្ញាវិញ វីលៀម ស្មីត បានជំទាស់ដោយនិយាយថា ហ្វ្រង់ស្វ័រ រ៉ូ បានបង្កើតជាការចាប់អារម្មណ៍អវិជ្ជមានមួយទាក់ទិននឹងការចាត់ចែងកន្លែងអង្គុយ ។

លោកប្រធានចៅក្រមបានដោះស្រាយបញ្ហាកន្លែងអង្គុយរបស់មេធាវីថ្មីរូបនេះដោយពន្យល់ថា ទីកន្លែងអង្គុយរបស់មេធាវីដែលស្ថិតនៅក្បែរមេធាវីការពារក្តី គឺគ្រាន់តែកើតឡើងដោយចៃដន្យនោះទេ ព្រោះថា កន្លែងអង្គុយនោះអាចទុកកន្លែងទំនេរខ្លះដើម្បីឲ្យមេធាវីអាចធ្វើការបានស្រួល និងអាចឲ្យមេធាវីនៅក្បែរកូនក្តីរបស់ខ្លួនបានទៀតផងដែរ ។

## ពីគ្រូបង្រៀនមកជាអ្នកសួរចម្លើយ

ក្រោយពីបានឮ ឌុច និយាយពីពេលវេលាដែលអ្នកនៅក្រោមបង្គាប់គាត់បានអនុវត្តការផ្សារដ៏សាហាវយង់ឃ្នងនៅឯមន្ទីរស-២១ស្របពេលដែល ឌុច គ្រាន់តែធ្វើការផ្សារជាមួយនឹងប៊ិច និងក្រដាសនៅក្នុង

ការិយាល័យមក ខ្ញុំរំពឹងទុកថា ម៉ម ណៃ នឹងផ្តល់នូវសក្ខីកម្មដោយរៀបរាប់ពីប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរស-២១ និងដោយបង្ហាញថា ឌុច ពិតជាបានដឹងឮពីអំពើសាហាវឃោរឃៅ និងបានចេញបញ្ជាឲ្យប្រព្រឹត្តអំពើសាហាវឃោរឃៅទាំងអស់នោះជាពុំខាន ។ ផ្ទុយទៅវិញ ខ្ញុំបានគិតខុសទាំងស្រុង ។ ក្រោយពីការសួរសំណួររបស់ចៅក្រមទាំងបួននាក់ក្នុងរយៈពេលជាច្រើនម៉ោងមក ម៉ម ណៃ អាយុ ៧៩ឆ្នាំ បែរជានិយាយថា មន្ទីរស-២១គឺជាជោគជ័យមួយរបស់បក្សកុម្មុយនីស្តកម្ពុជាដោយធ្វើការអះអាងថា មន្ទីរស-២១មិនមានការធ្វើទារុណកម្មទេហើយអ្នកទោសទាំងអស់សុទ្ធតែមានសុខភាពល្អ ។

ម៉ម ណៃ គឺជាមនុស្សរបេះដឹងម្នាក់ ។ គាត់អាចនិយាយភាសាខ្មែរបានយ៉ាងល្អ ហើយអាចនិយាយភាសាអង់គ្លេស បារាំង និងវៀតណាមបានល្អគួរសមដែរ ។ ម៉ម ណៃ បានរៀនចប់ថ្នាក់វិទ្យាល័យមុនពេលគាត់ក្លាយជាគ្រូបង្រៀន ។ ក្រោយពេលចាប់ខ្លួននិងជាប់ឃុំមក ម៉ម ណៃ បានចំណាយពេលជាងពីរឆ្នាំក្នុងបន្ទប់ឃុំឃាំងជាមួយនឹង ឌុច មុននឹងត្រូវបានដោះលែងពីរបប លន់ នល់ ។ ក្រោយពីបាតុកម្មនៅឆ្នាំ១៩៧៣ដែលទាហាន លន់ ណុល បានបាញ់កាំភ្លើងមកលើពួកបាតុករមក ម៉ម ណៃ ក៏បានរត់ភៀសខ្លួនចូលក្នុងព្រៃដើម្បីរៀនមនោគមវិជ្ជាបដិវត្តជាមួយនឹង ឌុច និងមនុស្សម្នាផ្សេងទៀត ។ ក្រោយមក ឌុច បានជ្រើសរើស ម៉ម ណៃ ឲ្យមកធ្វើការជាមួយនៅមន្ទីរសន្តិសុខម-១៣ដែលមាន ឌុច ជាអ្នកគ្រប់គ្រង ។ ដំបូង ម៉ម ណៃ គ្រាន់តែបំពេញការងារតូចតាចប៉ុណ្ណោះ ប៉ុន្តែអស់មួយរយៈពេលក្រោយមក ម៉ម ណៃ បានរៀនពីវិធីសាស្ត្រសួរចម្លើយលើ«អ្នកដែលស្អប់បដិវត្ត» ដោយធ្វើការសង្កេតសកម្មភាពរបស់ ឌុច ។

ប្រហែលជាមួយខែក្រោយពីខ្មែរក្រហមបាន«រំដោះ»ទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ម៉ម ណៃ បានចាកចេញពីមន្ទីរសន្តិសុខម-១៣ជាមួយ ឌុច ដើម្បីចូលរួមស្ថាបនាគុកថ្មីមួយទៀតគឺមន្ទីរស-២១ ។ នៅមន្ទីរស-២១ ម៉ម ណៃ ត្រូវបានចាត់តាំងឲ្យសួរចម្លើយអ្នកទោសដែលចាត់ទុកថាជា«អ្នកទោស មិនសំខាន់»មានដូចជាសេនាជន និងកម្មាភិបាលថ្នាក់ទាប ។ ជាមួយគ្នានេះ ម៉ម ណៃ ក៏ត្រូវបានចាត់ តាំងឲ្យសួរចម្លើយទាហានវៀតណាម និងប្រជាជនវៀតណាមធម្មតាដែលចាប់ខ្លួនបាននៅសមរភូមិ ដោយសារតែ ម៉ម ណៃ ចេះនិយាយភាសាវៀតណាម ។ អ្នកទោសត្រូវបានដាក់ខ្នោះចងបិទភ្នែក និងនាំមកកាន់ផ្ទះសួរចម្លើយដែលស្ថិតនៅខាងក្រៅបរិវេណមន្ទីរស-២១ដែលជាកន្លែង ម៉ម ណៃ ធ្វើ ការតែម្នាក់ឯង ។ អ្នកយាមគ្រាន់តែមានតួនាទីរង់ចាំនៅខាងក្រៅផ្ទះសួរចម្លើយដោយមិនហ៊ានជ្រៀត ជ្រែកអ្វីឡើយ ។

ក្នុងរយៈពេលពេញមួយថ្ងៃនេះ ម៉ម ណៃ បានផ្ដើការសង្កត់ធ្ងន់ពីវិធីសាស្ត្រសួរចម្លើយដែលគាត់បានអនុវត្តនិងការបង្ខាប់ឲ្យសួរចម្លើយដែលទទួលបាន។ ម៉ម ណៃ បាននិយាយថា ជាទូទៅគាត់មិនដែលទទួលបានការបង្គាប់អ្វីទាក់ទិននឹងវិធីសាស្ត្រសួរចម្លើយ ប៉ុន្តែមានម្ដងនោះគាត់ធ្លាប់បាន ឌុច ប្រាប់ឲ្យសួរព័ត៌មានទាក់ទងនឹងសមរភូមិពីទាហានវៀតណាមក្នុងរយៈពេលមួយខែ។ អ្នកសួរចម្លើយទាំងអស់មិនអនុញ្ញាតឲ្យពិភាក្សាគ្នាពីវិធីសាស្ត្រសួរចម្លើយរបស់ខ្លួននោះទេ។ សម្រាប់វិធីសាស្ត្រសួរចម្លើយរបស់ ម៉ម ណៃ វិញ គាត់គ្រាន់តែ«ប្រើនយោបាយ»ជាមួយនឹងអ្នកទោសដោយសួរសំណួរដដែលៗរហូតទាល់តែអ្នកទោសនោះព្រមសារភាព។ ជួនកាល ម៉ម ណៃ បានបញ្ជូនអ្នកទោសទៅកាន់បន្ទប់ឃុំឃាំងវិញ ដើម្បីទុកពេលឲ្យអ្នកទោស«រំពឹក»សកម្មភាពដែលបានធ្វើមុននឹងត្រឡប់មកសួរចម្លើយម្ដងទៀត។ ម៉ម ណៃ បានអះអាងថា ការទាញយកប្រវត្តិរូបនិងចម្លើយសារភាពពីអ្នកទោស «មិនមែនជាកិច្ចការលំបាកអ្វីទេ» ហើយក៏មិនត្រូវការការគម្រាមគំហែងលើរូបរាងកាយរបស់អ្នកទោសដែរ។ នៅពេលដែលសួរថា តើនឹងមានរឿងអ្វីកើតឡើងប្រសិនបើមិនទទួលបានចម្លើយ ម៉ម ណៃ បាននិយាយថា គាត់នឹងរាយការណ៍ប្រាប់ ឌុច។ ម៉ម ណៃ មិនបាននិយាយថា ឌុច នឹងបញ្ជាឲ្យធ្វើអ្វីបន្តទៀតទេ ប្រសិនបើខ្លួនមិនអាចទាញយកចម្លើយបាន។ ម្យ៉ាងវិញទៀត ម៉ម ណៃ បានសរសេរចម្លើយសារភាពរបស់អ្នកទោសដោយដៃ។

ឌុច និងសាក្សីដទៃទៀតបាននិយាយនៅក្នុងអង្គជំនុំជម្រះថា ការបំពេញប្រវត្តិរូបនិងថតរូប ត្រូវបានធ្វើឡើងក្រោយពីការមកដល់មន្ទីរស-២១ភ្លាម។ ប៉ុន្តែ ម៉ម ណៃ បានឆ្លើយថា អ្នកទោសបានមកកាន់កន្លែងសួរចម្លើយដោយគ្មានឯកសារអ្វីភ្ជាប់មកជាមួយទេ។ មានន័យថា គាត់ចាប់ផ្ដើមសួរចម្លើយដោយគ្មានព័ត៌មានស្ដីពីប្រវត្តិរូបអ្នកទោសឡើយ។ នៅពេលដែលត្រូវសួរថា តើគាត់មានដឹងពីគោលនយោបាយរបស់មន្ទីរស-២១ដែលចែងថា អ្នកដែលជាប់ឃុំទាំងអស់គឺមានទោស ហើយអ្នកទាំងនោះត្រូវតែសម្លាប់ចោលនោះ ម៉ម ណៃ ឆ្លើយថា គាត់មិនដឹងពីរឿងនេះទេ។ ប៉ុន្តែក្រោយមក ម៉ម ណៃ បាននិយាយថា អ្នកទោសជនជាតិខ្មែរនៅមន្ទីរស-២១ទាំងអស់សុទ្ធតែបានប្រព្រឹត្តបទល្មើស«មិនថាធ្ងន់ឬស្រាល»ដែលប្រឆាំងនឹងបដិវត្ត។ ស្ដីពីអ្នកទោសជនជាតិវៀតណាមវិញ ម៉ម ណៃ បានចាត់ទុកអ្នកទាំងនោះថា មានទោសពីបទឈ្លានពានប្រទេសកម្ពុជា។ ម៉ម ណៃ ជឿថា ចម្លើយសារភាពដែលគាត់ទទួលបានគឺជាការពិត ប៉ុន្តែ«ការពិតនេះមានគុណភាពតិចតួចណាស់»។

## «ខ្ញុំមិនអាចនិយាយពីអ្វីដែលទាក់ទិននឹងបញ្ហានេះបានទេ!»

អត្ថន័យនៃឃ្លាខាងលើនេះហាក់បីដូចជាឆ្លុះបញ្ចាំងពីជំនឿរបស់ ម៉ម ណៃ ក្នុងការធ្វើសក្ខីកម្មនៅក្នុងថ្ងៃនេះ ។ សែសិបភាគរយនៃការឆ្លើយតបនឹងសំណួររបស់ចៅក្រម ម៉ម ណៃ គ្រាន់តែឆ្លើយថា គាត់មិនដឹង ឬក៏និយាយថា គាត់មិនមានសិទ្ធិដឹងពត៌ពីរឿងនេះទេ ឬថា គាត់មិនចាំទេ ។ ជាញឹកញាប់ ម៉ម ណៃ បានគូសបញ្ជាក់ថា គាត់គ្រាន់តែជា«កម្មាភិបាលសួរចម្លើយធម្មតានិងសាមញ្ញម្នាក់»តែប៉ុណ្ណោះ ហើយគាត់មិនត្រូវបានអនុញ្ញាតឲ្យ«ដើរហើរដោយសេរី»នៅក្នុងបរិវេណមន្ទីរស-២១ឡើយ ។ ម៉ម ណៃ បាននិយាយបន្តទៀតថា គាត់យកចិត្តទុកដាក់តែលើការងាររបស់គាត់តែប៉ុណ្ណោះ ហើយធ្វើពើរជាមនុស្ស«គរថ្លង់» ។ ម៉ម ណៃ បានបន្ថែមថា ប្រសិនបើគាត់ដើរសួរសំណួរអ្នកដទៃ ឬ«ដើររុករក»អ្វីដោយគ្មានការអនុញ្ញាត គាត់ប្រហែលជាមិនមានជីវិតរស់រានដូចសព្វថ្ងៃនេះទេ ។

ម៉ម ណៃ មិនអាចរៀបរាប់ពីការចាត់ចែងការងារនៅមន្ទីរស-២១ ចំនួនបុគ្គលិក ទីកន្លែងឃុំអ្នកទោស វិធីសាស្ត្រសួរចម្លើយ របៀបឃុំឃាំងអ្នកទោស និងហេតុការណ៍ដែលកើតឡើងចំពោះអ្នកទោសក្រោយពីឆ្លើយសារភាពនោះទេ ។ សូម្បីតែសម្លេងស្រែកនិងការសួរចម្លើយលើអ្នកទោសស្រី ក៏ ម៉ម ណៃ មិនចាំដែរ ។

បើទោះបីជាសក្ខីកម្មរបស់ ម៉ម ណៃ មានលក្ខណៈខុសឆ្ងាយពីសក្ខីកម្មដែលបានរៀបរាប់ឡើងកន្លងមកក៏ដោយ ក៏ការនិយាយដោះសារ និងការដឹងពត៌ដែលមានកម្រិតរបស់គាត់ហាក់បីដូចជាមានលក្ខណៈសមហេតុផលមួយភ្លែតដែរ ។ ប៉ុន្តែ ខ្ញុំពិតជាបាត់បង់នូវជំនឿជឿជាក់លើសក្ខីកម្មរបស់ ម៉ម ណៃ យ៉ាងខ្លាំងនៅពេលដែល ម៉ម ណៃ និយាយថាយោងតាមការអង្កេតរបស់គាត់ អ្នកទោសទាំងអស់មានសុខភាព«មិនស្គមពេក ហើយក៏មិនស្លេកស្លាំងណាស់ណាដែរ» ហើយមើលទៅដូចជាមាន«សុខភាពធម្មតា» ។ ជាក់ស្តែង អ្នកទោសមន្ទីរស-២១ទាំងអស់គឺសុទ្ធអត់អាហារហូប អត់ទឹកផឹក មានរបួសមានជម្ងឺ ហើយមានសុខភាពទ្រុឌទ្រោម ។

នៅពេលដែលចៅក្រម ខាតរ៉ាយថ៍ ចាប់ផ្តើមសួរសំណួរ ម៉ម ណៃ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា លោកស្រីចៅក្រមមានជំនឿតិចតួចណាស់លើសក្ខីកម្មរបស់ ម៉ម ណៃ ។ លោកស្រីចៅក្រមបានចំណាយពេលដប់នាទីបង្ហាញពីចំណេះដឹង និងកម្រិតការយល់ដឹងខ្ពស់របស់ ម៉ម ណៃ មុននឹងសួរ ម៉ម

ណៃ ថា តើការដែលនិយាយថា ម៉ម ណៃ ជាមនុស្ស“មានចំណេះដឹងខ្ពស់” “ឆ្លាត” ហើយប្រហែលជាមនុស្សដែលឈ្លាសវៃជាងគេនៅមន្ទីរស-២១នេះមានលក្ខណៈត្រឹមត្រូវដែរឬទេ។ បន្ទាប់មកទៀត លោកស្រីចៅក្រមបានធ្វើការពិនិត្យលើលក្ខណៈខុសគ្នារវាងការអះអាងរបស់ ម៉ម ណៃ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងសក្ខីកម្មដែល ម៉ម ណៃ កំពុងតែធ្វើឡើងនេះ។ សំណួររបស់ចៅក្រមខាតរ៉ាយថ៍ ហាក់បីដូចជាឆ្លុះបញ្ចាំងពីចម្ងល់មួយថា តើបុរសឆ្លាតម្នាក់នេះពិតជាខ្វះខាតការដឹងព្រមែនឬយ៉ាងណា។ ចៅក្រម ឡាវែន ក៏ចាប់ផ្ដើមសួរសំណួរទៅកាន់ ម៉ម ណៃ។ ក្រោយពីទទួលបានចម្លើយដែលមិនពេញចិត្តជាច្រើនដងមក លោកចៅក្រមក៏សួរ ម៉ម ណៃ ថា “តើអ្នកមានបញ្ហាចងចាំមែនដែរឬទេ”? ម៉ម ណៃ បានពន្យល់ថា ថ្មីៗនេះគាត់តែងតែភ្លេចភ្លាំងស្មារតី ក្រោយពេលដែលគាត់បានធ្លាក់ពីលើផ្ទះម្ដងមក។ ហើយចាប់តាំងពីពេលនោះមកគាត់មានបញ្ហាចងចាំរហូត។ ដោយសារតែសក្ខីកម្មរបស់ ម៉ម ណៃ ចៅក្រម ឡាវែន បានសន្និដ្ឋានពីរឿងរ៉ាវអាថ៌កំបាំងរបស់ ឌុច ទាក់ទិននឹងស្ថានភាពនិងដំណើរប្រតិបត្តិការរបស់មន្ទីរសន្តិសុខម-១៣។ លោកចៅក្រមក៏បានសួរ ម៉ម ណៃ ថា តើគាត់បានស្នាក់នៅកន្លែងតែមួយជាមួយនឹង ឌុច ដែរឬទេ? ម៉ម ណៃ បែរជាពន្យល់ថា ស្ថានភាពនៅក្នុងប្រទេសកម្ពុជាមានស្ថានភាពលំបាកណាស់នាពេលនោះ ហើយក៏បានបញ្ជាក់ប្រាប់ថា អ្នកទោសទាំងអស់ទទួលបានរបបអាហារតិចតួច ហើយខ្វះខាតសម្លៀកបំពាក់ជាងមនុស្សធម្មតា។

ក្រោយពីនៅស្ងៀមអស់រយៈពេលពេញមួយថ្ងៃ មេធាវីរបស់ ម៉ម ណៃ បានក្រោកឈរស្នើសុំសំណូមពរមួយចំពោះចៅក្រម ហើយភ្លាមៗនោះដែលចៅក្រមបានទទួលស្គាល់។ លោកមេធាវីបានស្នើសុំឲ្យមានការបង្ហាញឯកសារទាំងអស់ជំនួសឲ្យការបង្ហាញឯកសារតែមួយផ្នែកដើម្បីអនុញ្ញាតឲ្យ ម៉ម ណៃ យល់កាន់តែច្បាស់ហើយឆ្លើយនឹងសំណួរឲ្យកាន់តែប្រសើរឡើង។ លោកមេធាវីក៏បានបញ្ចេញមតិយោបល់បន្ថែមទៀត ប៉ុន្តែម្ដងនេះលោកមេធាវីទំនងជាខ្វះការយល់ដឹងពីដំណើរការនីតិវិធី និងពីរបៀបគ្រប់គ្រងរបស់អង្គសវនាការដោយគាត់បាននិយាយថា ចៅក្រមបានសួរសំណួរដដែលៗ ដែលធ្វើឲ្យគាត់មានការព្រួយបារម្ភពីប្រធានបទដែលភាគីទាំងអស់អាចនឹងលើកឡើង។ លើសពីនេះ មេធាវីរបស់ ម៉ម ណៃ បានស្នើឲ្យចៅក្រមផ្អាកដំណើរការនីតិវិធីដើម្បីពិនិត្យប្រភេទសំណួរសារជាថ្មីម្ដងទៀតដើម្បីធានាថា សំណួរទាំងនោះមានលក្ខណៈត្រឹមត្រូវ។ លោកមេធាវីរូបនេះបាននិយាយថា នៅក្នុងប្រព័ន្ធច្បាប់ពិសេសនេះគួរតែមានទម្រង់បែបបទច្បាស់លាស់មួយសម្រាប់ឲ្យភាគីទាំងអស់អនុវត្តតាម។

លោកប្រធានចៅក្រមទំនងជាព្យាយាមយល់ស្របចំពោះការព្រួយបារម្ភរបស់មេធាវី ។ លោកប្រធានបាននិយាយថា ចៅក្រមកំពុងតែអនុវត្តទៅតាមនីតិវិធីរបស់ច្បាប់កម្ពុជាដែលអាស្រ័យលើប្រព័ន្ធច្បាប់ស៊ីវិលឡ របស់បារាំង ។ លោកប្រធានបានពន្យល់ប្រាប់ទៀតថា ចៅក្រមត្រូវបានអនុញ្ញាតឲ្យសួរសំណួរលម្អិតទៅកាន់សាក្សី មុននឹងភាគីផ្សេងទៀតទទួលភារៈកិច្ចសួរសំណួរបន្តយោងទៅតាមពេលវេលាដែលបានប្រគល់ឲ្យ និងប្រធានបទដែលបានគូសបញ្ជាក់ដោយចៅក្រម ។

ឆ្លើយតបនឹងការអក់អន់ចិត្តរបស់ចៅក្រមចំពោះសក្ខីកម្ម ម៉ម ណៃ, ហ្វ្រង់ស័រ រូ បានឆ្លៀតឱកាសលើកឡើងពីសិទ្ធិរបស់សាក្សីយោងតាមវិធាន២៨សារជាថ្មីម្តងទៀត ។ ហ្វ្រង់ស័រ រូ បាននិយាយថា នេះគឺ ជាការល្អដែលថាសាក្សីគួរតែត្រូវបានរំឭកពីសិទ្ធិមិនធ្វើការឆ្លើយតបពីព្រោះថាវាអាចជួយឲ្យសាក្សីមិនឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ។ លោកប្រធានចៅក្រមបានឆ្លើយតបវិញថាចៅក្រមបានទទួលការណែនាំគ្រប់គ្រាន់ហើយ ហើយក៏បានដឹកនាំដំណើរការនីតិវិធីដោយត្រឹមត្រូវដែរ ។ មេធាវីក្រុមមួយ អាឡាំង វែនណឺ បាននិយាយថា ប្រសិនបើសាក្សីគួរតែត្រូវបានរំឭកពីសិទ្ធរបស់គេ នោះសាក្សីក៏គួរតែត្រូវបានរំឭកពីកាតព្វកិច្ចរបស់គេដែលមានចែងនៅក្នុងវិធាន៣៦ដែរ ។ យោងតាមវិធាន៣៦ ចៅក្រមអាចរំឭកសាក្សីពីកាតព្វកិច្ចរបស់គេដែលត្រូវនិយាយការពិត និងពន្យល់ពីមូលហេតុដែលខ្លួនបានប្រព្រឹត្ត ។ យោងតាមវិធាន៣៦.២ ប្រសិនបើចៅក្រមមានមូលហេតុក្នុងការជឿថា ការធ្វើសក្ខីកម្មមិនពិតគឺធ្វើឡើងដោយចេតនា នោះចៅក្រមអាចបញ្ជូនបញ្ហានេះទៅកាន់អាជ្ញាធរជាតិកម្ពុជា និងអាជ្ញាធរអង្គការសហប្រជាជាតិ ឬក៏ធ្វើការស៊ើបអង្កេតបន្ថែមទៀត ។

ថ្ងៃស្អែកនេះ ម៉ម ណៃ នឹងចូលមកបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះម្តងទៀតដើម្បីឲ្យព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីសួរសំណួរ ។